# ជនល្អ

*(បទពាក្យ ៧)*

*ជនណាគាស់ផ្តាច់នូវកំណាញ់ ដែលច្រណែនខ្នាញ់ក្រោធហឹង្សា*
*ជាជនបរិបូរណ៍ដោយប្រាជ្ញា តថាគតហៅថា ជនរូបល្អ ។*
*កោរសក់ហើយស្លៀកកាសាវៈ មិនជាសមណៈតាមច្បាប់ធម៌*
*ច្រណែនលោភៈមូលកុះករ ហៅសមណៈល្អដូចម្តេចបាន ។*
*ជនណាញ៉ាំងបាបទោះតូចធំ ឲ្យស្ងប់ជ្រងំចិត្តក្សេមក្សាន្ត*
*ព្រះហៅសមណៈប្រសើរថ្កាន បាបទាំងប៉ុន្មានបានរម្ងាប់ ។*
*មិនមែនភិក្ខុព្រោះតែសូម ធម៌មានពិសព្រមប្រកាន់ខ្ជាប់*
*ពួកកិលេសធម៌មិនរម្ងាប់ មិនរាប់ជាភិក្ខុព្រោះសូមនោះ ។*
*ជនណានៅក្នុងសាសនានេះ លះបុណ្យលះបាបព្រហ្មចារខ្ពស់*
*រស់នៅក្នុងលោកជំរុះអស់ ឈ្មោះថាភិក្ខុតាមវាទី ។*
*ជនដែលល្ងិតល្ងង់ទោះស្ងៀមស្ងាត់ គេក៏មិនចាត់ជាមុនី*
*អ្នកកាន់ជញ្ជីងថ្លឹងហេតុពីរ បាបបុណ្យទាំងទ្វីគឺបណ្ឌិត ។*
*ប្រាជ្ញកាន់យកធម៌ដ៏ឧត្តម វៀរបាបតូចធំគ្មានដាមជិត*
*ជនណាស្គាល់លោកទាំងពីរពិត នោះនាមពិសិដ្ឋហៅមុនី ។*
*ជនណាដែលនៅបៀតបៀនសត្វ មិនចាត់នាមជាព្រះអរិយ៍*
*អ្នកមិនបៀតបៀនសត្វប្រក្រតី ឈ្មោះថាអរិយ៍វៀងរហូតអើយ ។ល*